**សកម្មភាព** ៖ ល្បែងគោះដើរផ្សារ

**បុរេគណិត**

បំណិនពិចារណាក្នុងសង្គម (ចំណេះដឹងនៃបញ្ញត្តិសេដ្ឋកិច្ចសាមញ្ញមួយចំនួន)

**គោលបំណង** ៖

**(បុរេគណិត)** ៖ ប្រាប់ឈ្មោះ និងប្រភេទប្រាក់រៀលខ្មែរដូចជា១០០, ៥០០, ១០០០, ៥០០០រៀល និងលើសពីនេះក៏បាន។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង ៉តើអ្នកចង់ធ្វើការងារអ្វី? ៉

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖

- ដាក់សម្ភារសម្រាប់លក់នៅលើតុ ដោយមានសរសេរ ឬបិទតម្លៃនៅខាងមុខ។
- សូមកំណត់តម្លៃបន្ថែមក្នុងករណីអ្នកត្រូវការផ្លាស់ប្តូរតម្លៃខ្លះ ដូច្នេះត្រូវមាន ៤តម្លៃ (១០០, ៥០០, ១០០០, ៥០០០រៀល) សម្រាប់ជ្រើសរើសនៅលើតុ។

**ការរៀបចំ** ៖

- បោះពុម្ពរូបភាពក្រដាសប្រាក់ និងកាត់វាជាសន្លឹកផ្សេងៗគ្នា អ៊ុតក៏បានដែរ (១០០, ៥០០, ១០០០, ៥០០០រៀល) ។
- សម្ភារសម្រាប់ដាក់លក់ដូរ។
- សរសេរតម្លៃនៅលើសម្ភារដែលត្រូវលក់នោះ។

**សេក្តីណែនាំ៖**

1. ពិភាក្សាថា៖ ហេតុអ្វីបានជាមនុស្សធំត្រូវធ្វើការងារ?
   (ចម្លើយ៖ ពីព្រោះរកលុយដើម្បីទិញម្ហូបអាហារ សម្លៀកបំពាក់ និងផ្ទះជាដើម -ល-)។
2. ចែកក្រដាសប្រាក់ទៅឱ្យក្មេងៗ ម្នាក់មួយសន្លឹក។
   (ក្រដាស់ប្រាក់ធ្វើពីក្រដាស ១០០រៀល ៥០០រៀល ១០០០រៀល ៥០០០រៀល) ។
3. សួរក្មេងៗអំពីក្រដាសប្រាក់នីមួយៗ៖
   តើក្រដាសប្រាក់១០០ ៥០០ ១០០០ ៥០០០ រៀលមានពណ៌អ្វី?

តើមានរូបអ្វីជាសម្គាល់?

តើកូនមានក្រដាសប្រាក់(១០០ ៥០០ ១០០០ ៥០០០ រៀល) អាចទិញអ្វីបានខ្លះ?

4. ឱ្យក្មេងៗបង្ហាញក្រដាសប្រាក់ម្តងមួយប្រភេទតាមសន្លឹកនីមួយៗដែលអ្នកគ្រូសួរ ១០០ រៀល ៥០០ រៀល ១០០០ រៀល ៥០០រៀល ។ ឧទាហរណ៍៖ចូរកូនបង្ហាញក្រដាសប្រាក់ ១០០រៀល
5. ត្រូវរៀបចំរបស់របរនៅលើតុ ធ្វើដូចជាអ្នកលក់នៅផ្សារ។
6. បន្ទាប់មកប្រាប់ក្មេងៗថា៖ កូនៗនឹងលេងល្បែងតោះដើរផ្សារជាមួយអ្នកគ្រូ។ កូនត្រូវទិញរបស់របរនៅលើតុអ្នកគ្រូទាំងអស់គ្នា ។
7. ហៅក្មេងម្នាក់ ឬ ចែកជាក្រុមក៏បាន ឱ្យដើរមកតុអ្នកគ្រូ និងបង្ហាញក្រដាសប្រាក់ទៅមិត្តរួមថ្នាក់។ ហើយអ្នកគ្រូសួរក្មេងនោះថា៖ តើក្រដាសប្រាក់នេះមានតម្លៃប៉ុន្មាន?
8. ឱ្យក្មេងជ្រើសរើសរបស់មួយដែលត្រូវនឹងតម្លៃរបស់ក្រដាសប្រាក់ដែលក្មេងមាន។
9. ពេលក្មេងៗទាំងអស់ដល់វេនដើរផ្សារទិញគ្រប់គ្នាហើយនោះ សូមឱ្យក្មេងទាំងអស់ប្រគល់ក្រដាសប្រាក់ឱ្យគ្រូវិញជាការស្រេច។

**ការប្រែប្រួល៖**

សកម្មភាពនេះអាចលេងបានដោយវិធីផ្សេងទៀតបាន និងពិបាកតាមដែលអ្នកត្រូវការ។វិធីងាយស្រួលគឺជ្រើសរើសបោះពុម្ពរូបភាពក្រដាសប្រាក់ និងកាត់វាជាសន្លឹកផ្សេងៗគ្នា និងជ្រើសរើសរបស់របរដែលមានតម្លៃស្រាប់។

សម្រាប់ក្មេងដែលមានអាយុច្រើននោះគឺនិយាយពីក្រដាស១០០រៀល ពីរសន្លឹក ស្មើនឹង២០០រៀល។

ចែកក្រដាសប្រាក់ឱ្យទៅពួកគេ២ ឬ ៣ សន្លឹកមានតម្លៃដូចគ្នា សម្រាប់ឱ្យពួកគេចេះបូកចូលគ្នាផង។

ចែកក្រដាសប្រាក់ឱ្យទៅពួកគេ២ ឬ ៣ សន្លឹកមានតម្លៃមិនដូចគ្នា សម្រាប់ឱ្យពួកគេចេះបូកចូលគ្នាផង។